# លទ្ធផលសង្ខេបនៃសិក្ខាសាលារៀបចំចក្ខុវិស័យសម្រាប់ការផ្តល់សេវាសុខភាពប្រកបដោយប្រសិទ្ធភាព ឆ្នាំ២០៣០ នៅក្នុងបរិបទនៃអនុក្រឹត្យលេខ១៩៣ និង ក.ជ ២

## សង្ខេបប្រតិបត្តិ

កិច្ចសហការរវាង គ.ជ.អ.ប ក្រសួងសុខាភិបាល និង GIZ DAR បានរៀបចំធ្វើសិក្ខាសាលាអនឡាញប្រកបដោយភាពច្នៃប្រឌិតមួយដែលមានវគ្គអនឡាញចំនួន០៦វគ្គ រយៈពេលពីរសប្តាហ៍ (ប្រហែល 20 ម៉ោងតាមប្រព័ន្ធអនឡាន) ជាមួយសិក្ខាកាមសរុបចំនួន១១៥នាក់ក្នុងនោះមានស្រី១៧នាក់ពីថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតចក្ខុវិស័យសម្រាប់ការផ្តល់សេវាសុខភាពប្រកបដោយប្រសិទ្ធភាពត្រឹមឆ្នាំ 2030 និងពិភាក្សាស្វែងរកជម្រើសនានាក្នុងការពន្លឿនការអនុវត្តអនុក្រឹត្យលេខ១៩៣ និង ក.ជ២។ វិធីសាស្ត្រថ្មី និងប្រកបដោយភាពច្នៃប្រឌិតមួយត្រូវបានយកមកប្រើប្រាស់ក្នុងការសម្របសម្រួលសិក្ខាទាំងមូល ដែលមានឈ្មោះថាវិធីសាស្ត្ររៀបចំផែនការប្រកបដោយការលើកទឹកចិត្ត Appreciate Inquiry (AI) ទទួលបានការពេញចិត្តយ៉ាងខ្លាំងពីអ្នកចូលរួមនៃសិក្ខាសាលា។ សិក្ខាកាមបានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀនសូត្រអំពីវិធីសាស្ត្រថ្មីនេះដោយរៀនបណ្តើរ និងអនុវត្តបណ្តើរតាមជំហ៊ាន និងតំណាក់កាលនីមួយនៃវដ្តទាំងមូលនៃការរៀបចំផែនការប្រកបដោយការលើកទឹកចិត្ត AI (ការកំណត់ប្រធានបទ ការរកឃើញ ក្តីស្រមៃ រៀបចំផែនការ និងការអនុវត្តផែនការ)។ បញ្ហាប្រឈមបច្ចេកទេសមួយចំនួននៅថ្ងៃទី០១នៃសិក្ខាសាលាអនឡាញត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស ប៉ុន្តែបញ្ហានេះគួរតែត្រូវបានកាត់បន្ថយទាំងស្រុងនៅពេលរៀបចំសិក្ខាសាលាក្រោយៗទៀតនាពេលអនាគត។ ការថតវីដេអូអំពីការយល់ដឹងរបស់សិក្ខាកាមបានឆ្លុះបញ្ចាំងអំពីកម្រិតយល់ដឹង និងការចូលរួមរបស់សិក្ខាកាម ហើយបានបង្ហាញថាវិធីសាស្ត្រនេះជាទម្រង់ទំនាក់ទំនងដ៏ល្អមួយក្នុងការយកទៅប្រើប្រាស់សម្រាប់សិក្ខាសាលា ដែលមានចំនួនអ្នកចូលរួមច្រើន។ លើសពីនេះទៅទៀត ការផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សិក្ខាកាមចូលរួមពិភាក្សាតាមក្រុមតូចៗប្រកបដោយកិច្ចសហការ រួមជាមួយនិងការចែករំលែកឯកសារសម្រាប់អានជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការទទួលបានជោគជ័យក្នុងក្រុមពិភាក្សា ។

ចក្ខុវិស័យដែលបានបង្កើតបានកំណត់ប្រធានបទសំខាន់ៗទាំងនេះ៖

- ការរៀបចំឲ្យមានការផ្លាស់ប្តូរព័ត៌មាន និងការពិភាក្សាឲ្យបានញឹកញាប់រវាងមន្ត្រីបច្ចេកទេសជំនាញ និងមន្ត្រីរដ្ឋបាលនៃថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឆ្លុះបញ្ចាំងលើប្រធានបទសំខាន់នៃកំណែទម្រង់វិស័យសុខាភិបាល
- លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងចលករថ្មីក្នុងការនាំយកសេវាសុខភាពកាន់តែខិតជិតដល់ប្រជាពលរដ្ឋ។

- ការស្វែងរកជម្រើសនានាក្នុងការបង្កើនប្រភពហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឧទហណ៍ ភាពជាដៃគូរដ្ឋ និងឯកជន (ភ.រ.ជ) និងគំរូផ្តល់សេវាសុខាភិបាលក្រោមកម្មសិទ្ធិ/ ការគ្រប់គ្រងរបស់ខេត្ត
- ការកែប្រែរចនាសម្ព័ន្ធរដ្ឋបាល និងអង្គការ ឧទាហរណ៍ ការគ្រប់គ្រងឪជីថលរួមនៃរថយន្តសង្គ្រោះបន្ទាន់ ឬការរួមបញ្ចូលមណ្ឌលសុខភាពទៅក្នុងរចនាសម្ព័ន្ធនៃមន្ទីរពេទ្យបង្អែកស្រុក
- ការពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសជំនាញនៅថ្នាក់ក្រោមជាតិតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលា

ចក្ខុវិស័យខាងលើក៏ជាការបង្ហាញពីក្របខណ្ឌទំនាក់ទំនងថ្មីដែលអាចបម្រើជាប្រភពនៃព័ត៌មានសម្រាប់ការសិក្សាជាច្រើនដែលរំលេចនៅក្នុង NPII និងទទួលបានការយល់ដឹងស៊ីជម្រៅអំពីប្រធានបទសំខាន់ៗទាំងនេះ ដោយការសិក្សាស្វែងយល់បន្ថែម និងចាប់ផ្តើមការអនុវត្តជំហ៊ានដំបូងដូចជាៈ

**ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស៖**

អភិវឌ្ឍសមត្ថភាពទៅលើភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងសមត្ថភាពអ្នកគ្រប់គ្រងគ្លីនិក និងបុគ្គលិកពេទ្យ ដើម្បីផ្តល់សេវាសុខាភិបាលនៅតាមមន្ទីរពេទ្យបង្អែកខេត្ត/ ស្រុក ឲ្យកាន់តែរលូន និងប្រកបដោយភាពរួសរាយរាកទាក់ ព្រមទាំងការពង្រាយវិជ្ជបណ្ឌិតនៅតាមមណ្ឌលសុខភាពឲ្យបានប្រសើរជាងមុន ដើម្បីសម្រួលដល់ការផ្តល់សេវាបឋមមួយចំនួន ដែលក្នុងន័យនេះ គឺយើងអាចបង្វិតសេវាកាន់តែគៀកនឹងប្រជាពលរដ្ឋ។

**ការផ្ទេរធនធានហិរញ្ញវត្ថុ និងការស្វែងរកម្រើសនានាក្នុងការបង្កើនប្រភពហិរញ្ញវត្ថុ៖**

ស្វែងរកជម្រើសនានាក្នុងការអនុវត្តភាពជាដៃគូរដ្ឋ និងឯកជន (ភ.រ.ជ) និងគំរូផ្តល់សេវាសុខាភិបាលក្រោមកម្មសិទ្ធិ/ ការគ្រប់គ្រងរបស់ខេត្ត។ ធ្វើឲ្យប្រសើរឡើងដល់គុណភាពសេវា ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈបរិក្ខា ដើម្បីទាក់ទាញអ្នកជម្ងឺដែលមានចំណូលខ្ពស់ងាកមកប្រើប្រាស់សុខាភិបាលសាធារណៈវិញ ដូចនេះចំណូលរបស់សេវាសុខាភិបាលសាធារណៈនឹងមានការកើនឡើង។ ការណែនាំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឌីជីថល និងការអនុវត្តធនធានមនុស្ស បង្កើនទំនុកចិត្ត និងគណនេយ្យភាពនៅក្នុងប្រព័ន្ធ។ ស្វែងយល់ពីរបៀបបង្កើនប្រាក់ចំណូលពីធនធានស្របច្បាប់ដែលមានស្រាប់ ដូចជា កម្រៃសេវាពីអ្នកប្រើប្រាស់ មូលនិធិសមធម៌ មូលនិធិសន្តិសុខសង្គម (ប .ស.ស.) សប្បុរសជន ក្រុមហ៊ុនធានារ៉ាប់រង ជាដើម។ល។

**បច្ចេកវិជ្ជាឌីជីថល៖**

ការប្រើក្របខណ្ឌផែនការ និងទំនាក់ទំនងឌីជីថល ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិជ្ជឌីជីថល និងសេវាកម្មឌីជីថលទំនើបឱ្យកាន់តែជិតស្និទ្ធជាមួយប្រជាពលរដ្ឋ។ ឧទាហរណ៍ៈ រដ្ឋបាលខេត្តណែនាំប្រព័ន្ធកំណត់ត្រាអ្នកជំងឺដែលគ្រប់គ្រងដោយ App និងអាចកំណត់ត្រាអ្នកផ្តល់សេវាសុខភាពផ្សេងៗ

ដោយធ្វើឱ្យទិន្នន័យវេជ្ជសាស្ត្រទាំងអស់មានសម្រាប់អ្នកផ្តល់សេវារៀងៗខ្លួន និងបើកការទំនាក់ទំនងផ្ទាល់ (និង ប្រតិបត្តិការហិរញ្ញវត្ថុ) រវាងអ្នកជំងឺនិងអ្នកផ្តល់សេវា។ ការប្រើប្រាស់បច្ចេកវិជ្ជាឌីជីថលសម្រាប់ការកែលម្អគុណភាព សេវាសុខភាព ដូចជាប្រព័ន្ធកំណត់ត្រាទិន្នន័យអ្នកជំងឺឌីជីថល ប្រព័ន្ធគ្រប់គ្រងព័ត៌មានជំងឺ ប្រព័ន្ធគ្រប់គ្រង ធនធានមនុស្ស ប្រព័ន្ធអេឡិចត្រូនិចដើម្បីកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ ប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន សុខភាពគេហទំព័រ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឌីជីថល។

<u>ការផ្ទេរមុខងារ និងការរៀបចំរចនាសម្ព័ន្ធឡើងវិញ</u>៖

ស្វែងរកជំម្រើសផ្សេងៗក្នុងការរៀបចំឡើងវិញនូវការផ្តល់សេវារថយន្តសង្គ្រោះក្រោមអង្គភាពស្របច្បាប់មួយ ដែលបង្កើនលទ្ធភាពប្រើប្រាស់ និងគុណភាព រួមផ្សំជាមួយ App សម្រាប់ហៅរថយន្តសង្គ្រោះទាន់ពេល។ ធ្វើការសិក្សាលទ្ធភាពនៃការរៀបចំឡើងវិញនូវមណ្ឌលសុខភាព ដើម្បីជាផ្នែកនៃមន្ទីរពេទ្យបង្អែកស្រុក ឬខេត្ត ដើម្បីផ្តល់សេវាកាន់តែជិតស្និទ្ធជាមួយប្រជាពលរដ្ឋតាមរយៈការបញ្ជូនអ្នកជំងឺ និងការធ្វើឲ្យប្រសើរឡើងដល់ការទំនាក់ទំនងរវាងកន្លែងទាំងនេះ ដើម្បីបង្កើនគុណភាពសេវាកម្ម។ បែងចែកអ្នកគ្រប់គ្រង និងបុគ្គលិកសុខាភិបាលឡើងវិញ ដោយផ្អែកលើការវាយតម្លៃតម្រូវការ ដោយប្រើប្រព័ន្ធរួមបញ្ចូលគ្នារវាងប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែក ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខេត្ត និងរាជធានី។ ធ្វើតេស្តសាកល្បងលើការបង្កើតស្ថាប័នរដ្ឋបាលសាធារណៈ គំរូផ្តល់សេវាសុខាភិបាលក្រោមកម្មសិទ្ធិ/ ការគ្រប់គ្រងរបស់ខេត្ត និងគំរូនៃការអនុវត្តភាពជាដៃគូរដ្ឋ និងឯកជន (ភ.រ.ជ) សម្រាប់មន្ទីរពេទ្យខេត្ត។

<u>ការកែលម្អការទំនាក់ទំនង</u>៖

ដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធ និងដំណើរការដើម្បីពង្រឹងការទំនាក់ទំនងរវាងអាជ្ញាធររដ្ឋបាលមូលដ្ឋាន (ក្រុមប្រឹក្សា, គណៈអភិបាល...។ល។) និងបុគ្គលិកជំនាញបច្ចេកទេស (បុគ្គលិកសុខាភិបាលៈ មន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព) នៅថ្នាក់ខេត្ត និងស្រុក។ ដាក់ឲ្យប្រើប្រាស់នូវយន្តការទំនាក់ទំនងរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួល ផ្លាស់ប្តូរមតិយោបល់ និងបទពិសោធន៍នានា ដើម្បីធានាបាននូវទំនុកចិត្ត និងសុវត្ថិភាពផ្នែកសតិអារម្មណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួលយកភាពជាម្ចាស់ និងគំនិតច្នៃប្រឌិតនានា។ បង្កើតសិក្ខាសាលាឆ្លុះបញ្ចាំងជាទៀងទាត់សម្រាប់សមិទ្ធផល និងឱកាសសម្រាប់ការអភិវឌ្ឍឆ្ពោះទៅមុខ ដោយមានការគាំទ្រពីថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការទទួលបានការយល់ដឹងទូលំទូលាយអំពីគោលនយោបាយបច្ចេកទេស បញ្ហាប្រឈមសុខភាព និងការងាររដ្ឋបាល ដូច្នេះភាគីទាំងពីរអាចយល់ និងឯកភាពគ្នាទៅវិញទៅមក។ ដាក់ឲ្យប្រើប្រាស់នូវបច្ចេកវិជ្ជា E-Government ដើម្បីពន្លឿនដំណើរការទំនាក់ទំនងរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧ. លិខិតអញ្ជើញ និងលិខិតផ្លូវការផ្សេងៗ) ដោយអាចប្រើលិខិតស្កេន ដែលបានបញ្ជូនក្នុងកម្មវិធី Telegram/WhatsApp ជំនួស ឬ រង់ចាំលិខិតផ្លូវការមកដល់។

**ជំហានបន្ទាប់៖**

១. រៀបចំគោលគំនិតមួយ និងបង្កើតយន្តការទំនាក់ទំនងដ៏ទូលំទូលាយរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាក្របខ័ណ្ឌសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍ សិក្សាស្វែងយល់ និងអនុវត្តការសាកល្បងលើប្រធានបទដែលបានរៀបរាប់ខាងលើ។ គួជ្រើសយកវិធីសាស្ត្រ ដែលមានលក្ខណៈវិជ្ជមាន និងសកម្មស្រដៀងគ្នាដូចនឹងវិធីសាស្ត្ររៀបចំផែនការតាមបែបការលើកទឹកចិត្ត (AI) ដែលបានប្រើក្នុងសិក្ខាសាលារៀបចំចក្ខុវិស័យនេះ។ វិធីសាស្ត្រនេះក៏អាចជាជម្រើសមួយក្នុងការផ្តល់ព័ត៌មានស្តីអំពីការសិក្សាផ្សេងៗដែលបានលើកឡើងក្នុង **ក.ជ ២** សម្រាប់វិស័យសុខាភិបាលផងដែរ។

២. ជាតំបូងបង្អស់ គួផ្តោតទៅលើការរៀបចំឲ្យមានយន្តការទំនាក់ទំនង ឬក្រុមការងារក្នុងការយកប្រធានបទខាងលើមកពិភាក្សា និងដោះស្រាយ ដូចជាបញ្ហាលិខិតអញ្ជើញ ការរៀបចំសេវាឡានសង្គ្រោះឡើងវិញ មុននឹងឈានទៅរកប្រធានបទស្មុគស្មាញ ដូចជាការការបញ្ចូលរចនាសម្ព័ន្ធមណ្ឌលសុខភាពទៅក្នុងមន្ទីរពេទ្យបង្អែកខេត្ត/ ស្រុក និងការបង្កើតការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ឬបែងចែកអ្នកគ្រប់គ្រងសុខភាព/ បុគ្គលិកសុខាភិបាលឡើងវិញដោយផ្អែកលើតម្រូវការ។

៣. ប្រធានបទសំខាន់មួយនៅក្នុងប្រធានបទភាគច្រើនគឺបច្ចេកវិជ្ជាឌីជីថល ដែលជាកត្តាជំរុញសំខាន់មួយក្នុងការនាំយកសេវាសុខាភិបាលឲ្យកាន់តែជិតស្និទ្ធជាមួយប្រជាពលរដ្ឋ។ វេទិកាទំនាក់ទំនងគួរតែត្រូវបានប្រើដើម្បីសិក្សាស្វែងយល់ និងបង្កើតជម្រើសផ្សេងៗ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ វេទិកានេះគួរតែត្រូវបានប្រើដើម្បីស្វែងរកសម្ព័ន្ធភាពជាយុទ្ធសាស្ត្រជាមួយអ្នកពាក់ព័ន្ធ ដែលមានសក្តានុពលក្នុងការរួមចំណែលដល់ការផ្លាស់ប្តូរនេះ។